## ២- គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១បាន៖

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធាន និងសម្តេចបិុលបញ្ញា**សុខ អាន** ជាអនុប្រធាន។ នៅឆ្នាំ២០១៣ ការងារជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដោយមានឯកឧត្តមឧបនាយករដ្ឋមន្ត្រី**យឹម ឆៃលី** ជាប្រធាន។ ជាបន្តបន្ទាប់ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិនេះក៏ត្រូវបានធ្វើវិសោធនកម្មដោយកែសម្រួលមាត្រា១ និងមាត្រា២ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ក្រោយពីគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ។

### សមិទ្ធិផលការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានភ១.ផ១ រយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧-២០២៣)

### ក-ការងាររៀបចំឯកសារគតិយុត្ត ឯកសារគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រនានា

បានរៀបកែសម្រួល និងបង្កើតឯកសារគតិយុត្តិមួយចំនួនឱ្យស្របតាមស្ថានភាពការងារប្រចាំថ្ងៃ

- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រាទី១ និងមាត្រាទី២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- អនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- សេចក្តីសម្រេចលេខ៩៩ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
-សេចក្តីសម្រេចលេខ០៥ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- ប្រកាសលេខ៥២ ប្រក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាន របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បានដឹកនាំ និងបង្កើតក្រុមការងារបច្ចេកទេសជំរុញចលនាភូមិបួយផលិតផលមួយចំនួន១០ក្រសួង រួមមានក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រសួងពត៌មាន ក្រសួងផែនការ និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- បានដឹកនាំ និងបង្កើតគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១រាជធានី-ខេត្ត ចំនួន២៥ខេត្ត រាជធានី
- បានដឹកនាំ និងបង្កើតក្រុមការងារដឹកនាំ សម្របសម្រួលការងារចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយចំនួន៤ក្រសួង រួមមានក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍
- បានរៀបចំឯកសារគោលនយោបាយជាតិស្តីពី ការជំរុញចលនាភូមិមួយផលិតផលមួយ២០១៦-២០២៦

- បានរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ៥ឆ្នាំលើកទី១ ២០១៩-២០២៣

- បានរៀបចំគោលការណ៍ណែនាំស្តីពីការចងក្រងសមាជិកចលនាភូមិ១ផលិតផល១

**ខ- ការងាររៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ**

បានរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ ថ្ងៃទី៩ មេសា ជារៀងរាល់ឆ្នាំ បានចំនួន៤លើក និងរៀបចំឱ្យមានគោលការណ៍រួមស្តីពីការរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ ផលិតផលខ្មែរនៅទូទាំងប្រទេស។

- លើកទី១ ឆ្នាំ២០១៨ ក្រោមប្រធានបទ "យើងនាំប្រើប្រាស់ផលិតផលខ្មែរ "
- លើកទី២ ឆ្នាំ២០១៩ ក្រោមប្រធានបទ "យើងនាំគ្នាគាំទ្រ និងប្រើប្រាស់ផលិតផលខ្មែរ "
- លើកទី៣ ឆ្នាំ២០២០ ក្រោមប្រធានបទ"លើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ គឺលើកកម្ពស់ការផលិតវត្ថុធាតុដើមកែច្នៃ និងទិញផលិតផលខ្មែរ"
- លើកទី៤ ឆ្នាំ២០២១ ក្រោមប្រធានបទ "រួមគ្នាទិញនិងប្រើប្រាស់ផលិតផលខ្មែរ គឺរួមគ្នាលើកកម្ពស់កិត្យានុភាពជាតិ"

**គ- ការងារចងក្រងផលិតផលភូមិមួយផលិតផលមួយ**

បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ រាជធានី ខេត្ត ក្នុងការងារប្រមូលចងក្រងសមាជិកចលនាភូមិ១ផលិតផល១ នៅទូទាំងប្រទេស ដោយគិតនៅឆ្នាំ២០២១នេះ គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ បានចងក្រងផលិតផលភូមិមួយផលិតផលមួយបានចំនួន១២០មុខ ដែលក្នុងនោះជាផលិតផលិតរបស់ខេត្តចំនួន១០ រួមមានខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តព្រៃវែង និងខេត្តសៀមរាប។

**ឃ- ការងាររៀបចំព្រឹត្តិការកម្រិតជាតិ អន្តរជាតិ និងពិព័រណ៌ផលិតផលខ្មែរ**

បានសហការយ៉ាងជិតស្និតជាមួយក្រសួងពាណិជ្ជកម្ម វិស័យឯកជននានា ក្នុងការរៀបចំតាំងពិព័រណ៌ផលិតផលខ្មែរ ផលិតផលភូមិ១ផលិតផល១ នៅតាមបណ្តារាជធានី ខេត្តទូទាំង២៥រាជធានី ខេត្ត ព្រមទាំងចូលរួមព្រឹត្តិការណ៍ពិព័រណ៍កម្រិតថ្នាក់ជាតិ និងអន្តរជាតិជាច្រើនផងដែរ។

**ង- ការងារកសាងសមត្ថភាព និងបណ្តុះបណ្តាល**

- បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញនិងសហគ្រិនភាពដល់អាជីវករ សិប្បករ កសិករ សេវាករ នៅតាមបណ្តារាជធានី ខេត្តទាំង២៥។
- បានរៀបចំបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ភ១.ផ១ ទៅចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល វេទិកាជាតិ និងអន្តរជាតិនានា ជារៀងរាល់ឆ្នាំ។

**ច- ការងារកិច្ចសហប្រតិបត្តិការបរទេស វិស័យឯកជន និងសង្គមស៊ីវិល**

- បានសហការជាមួយទីភ្នាក់ងារសហប្រតិបត្តការអន្តរជាតិថៃ (TICA) លើគម្រោងសាងសង់មជ្ឈមណ្ឌលភូមិភាគលើកកម្ពស់ចលនាភ១.ផ១ នៅខេត្តកំពង់ចាម ដែលគ្រោងនឹងចាប់ផ្តើមដំណើការសោងសង់នាពេលឆាប់ៗខាងមុខនេះ។
- បានសហការ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងវិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសិក្សាស្រាវជ្រាវ ក្នុងគោលបំណងរួមគ្នាលើកកម្ពស់ចលនាភូមិ១ ផលិតផល១នៅកម្ពុជា ៖
- កិច្ចព្រមព្រៀងទ្វេភាគីជាមួយសមាគមពាណិជ្ជករដឹកជញ្ជូនទំនិញ

- កិច្ចព្រមព្រៀងទ្វេភាគីជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- កិច្ចព្រមព្រៀងទ្វេភាគីជាមួយរាជបណ្ឌិត្យសភាកម្ពុជា

**ឆ- ការងារផ្សព្វផ្សាយ ចែករំលែកពត៌មាន និងចំណេះដឹង**

- បានបង្កើតវេបសាយរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយអាស័យដ្ឋាន www.ovopnationalcommittee.gov.kh

- បានបង្កើតPage Facebook របស់អគ្គលេខាធិការដ្ឋានភ១.ផ១ ដែលមានឈ្មោះOVOP National Committee Cambodia ដែលបច្ចុប្បន្នមានចំនួន1,802like និង1,843 follow និងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់ view ក្នុងមួយ post

- បានបង្កើតChanel telegram ដែលមានឈ្មោះ OVOP National Committee Cambodia ដែលមានចំនួនសមាជិក២៣២ subscribers និងមានអ្នកចូលមើលចំនួនចាប់ពីខ្ទង់រយដល់ពាន់ view ក្នុងមួយ post

- បានបង្កើតក្រុមការងារភ១.ផ១ អន្តរក្រសួងតាមរយៈគ្រុបTelegram ដើម្បីងាយស្រួលទំនាក់ទំនង និងចែករំលែកពត៌មាន

- បានបង្កើតក្រុមការងារលេខាធិការដ្ឋានភ១.ផ១ រាជធានីខេត្ត តាមរយៈគ្រុប Telegram ដើម្បីងាយស្រួលទំនាក់ទំនង និងចែករំលែកពត៌មាន

- បានបង្កើតបណ្តាញក្រុមការងារជាច្រើនទៀតជាមួយក្រុមអាជីវករ សិប្បករ សមាគមន៍ សហគមន៍ អ្នកផ្តល់សេវា និងក្រុមការងារនិស្សិតជាដើម

**ចំណុចទី៣- ការរៀបចំនិងការអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន**

រាជរដ្ឋាភិបាលបាន សម្រេចបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជនដើម្បីដោះស្រាយសំណើនានា រួមមាន(១)- ក្រុមការងារផ្នែកកសិកម្ម កសិឧស្សាហកម្ម ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២)- ក្រុមការងារផ្នែកទេសចរណ៍ ដឹកនាំដោយឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ (៣)- ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា ដឹកនាំដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (៤)- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច ដឹកនាំដោយឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៥)- ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា (៦)- ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន (៧)- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម (៨)- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (៩)- ក្រុមការងារផ្នែកស្រូវ អង្ករ ដឹកនាំដោយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (១០)- ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល (១១)- ក្រុមការងារផ្នែកអប់រំ ដឹកនាំដោយឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (១២)- ក្រុមការងារផ្នែកសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង(១៣)- ក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ ដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។